ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

№ ៣៤០ ឧរថ.ករធថ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៤

# ប្រកាស
## ស្តីពីការចុះបញ្ជី និងលក្ខខណ្ឌនៃការផ្តល់ ការពន្យារបន្ត និង ការផ្ទេរសិទ្ធិ នៃអាជ្ញាប័ណ្ណធនធានរ៉ែ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញ អនុក្រឹត្យលេខ ៣៥ អនក្របក ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## សំរេច

**ប្រការ ១.-**

ប្រជាពលរដ្ឋខ្មែរ ឬរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងដាក់ពាក្យសុំអាជ្ញាប័ណ្ណធនធានរ៉ែ រួមមាន:

១- អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ

២- អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម

៣- អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ

៤- អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ និង

៥- អាជ្ញាប័ណ្ណស្វែងរុករក

ដើម្បីស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែ ឬកែច្នៃធនធានរ៉ែ ឬមានបំណងទទួលការផ្ទេរសិទ្ធិពីសម្បទានិកណាមួយដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវធ្វើការចុះបញ្ជីជាមុន នៅតាមទីកន្លែងដូចខាងក្រោម៖

ក- សំរាប់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ - ត្រូវធ្វើការចុះបញ្ជីនៅមន្ទីរ ឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុងដែលតំបន់សំរាប់ធ្វើការស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែនោះតាំងនៅ លើកលែង

តែបែបបទនៃការចុះបញ្ជីសំរាប់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ ដែលត្រូវកំណត់នៅក្នុងប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីប្រតិភូកម្មអំណាចនៃការងារឧស្សាហកម្ម រ៉ែ និងថាមពល ជូនដល់បណ្តាស្រុកនៃខេត្តមួយចំនួន។

ខ- សំរាប់អាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត - ត្រូវធ្វើការចុះបញ្ជី នៅអគ្គនាយកដ្ឋានធនធានរ៉ែនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

អគ្គនាយកដ្ឋានធនធានរ៉ែ និង មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីក្នុងរយៈពេលប្រាំពីរ (០៧) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសំណុំលិខិតសុំចុះបញ្ជីគ្រប់គ្រាន់ ដូចបានកំណត់ក្នុងប្រកាសនេះ ។

**ប្រការ ២.-**

សំណុំលិខិតសុំចុះបញ្ជីសំរាប់អាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបានកំណត់ដូចខាងក្រោម :

២.១ សំរាប់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ និងអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ត្រូវរួមមាន :

(ក) ពាក្យសុំចុះបញ្ជី ( មានបិទតែម ១.០០០រៀល) .................................. ចំនួន ១ច្បាប់

(ខ) ប្រវត្តិរូបមានបិទរូបថត៤x៦ ដោយមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ........ ចំនួន ១ច្បាប់

(គ) ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ ប័ណ្ណគ្រួសារ ដោយមានការបញ្ជាក់ចម្លងត្រឹមត្រូវតាមច្បាប់ដើម ................................................ ចំនួន ១ច្បាប់

២.២ សំរាប់អាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត ត្រូវរួមមាន :

(ក) ពាក្យសុំចុះបញ្ជី ( មានបិទតែម ១.០០០រៀល) .................................. ចំនួន ១ច្បាប់

(ខ) ប្រវត្តិរូបមានបិទរូបថត៤x៦ ដោយមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ....... ចំនួន ១ច្បាប់

(គ) ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ ច្បាប់ចម្លងលិខិតឆ្លងដែនដែលមានសុពលភាពដោយមានការបញ្ជាក់ចម្លងត្រឹមត្រូវតាមច្បាប់ដើម ................ ចំនួន ១ច្បាប់

(ឃ) លិខិតបញ្ជាក់អាស័យដ្ឋានក្រុមហ៊ុន ដោយមានការបញ្ជាក់ពីសាលាខេត្ត-ក្រុង ចំនួន ១ច្បាប់

(ង) ច្បាប់ចម្លងវិញ្ញាបនប័ត្រចុះបញ្ជីការនៅក្រសួងពាណិជ្ជកម្ម ដោយមានការបញ្ជាក់ចម្លងត្រឹមត្រូវតាមច្បាប់ដើម ............................................ ចំនួន ១ច្បាប់

(ច) ច្បាប់ចម្លងលក្ខន្តិកៈសហគ្រាសចំរុះ ....................................................ចំនួន ១ច្បាប់
( ហើយប្រសិនបើជាក្រុមហ៊ុនសហគ្រាសចំរុះ ត្រូវលំអិតពីទំនាក់ទំនងការទទួលខុសត្រូវចំណែកភាគហ៊ុន និងការចាត់តាំងជាការីប្រតិបត្តិ ...........................ចំនួន ១ច្បាប់ )

**ប្រការ ៣.-**

ប្រជាពលរដ្ឋខ្មែរ ឬ រូបវ័ន្តបុគ្គល ឬ នីតិបុគ្គល ដែលបានចុះបញ្ជីរួច អាចដាក់ពាក្យសុំអាជ្ញាប័ណ្ណធនធានរ៉ែ នៅតាមទីកន្លែង ដូចខាងក្រោម :

ក- សំរាប់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ - ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណ នៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ដែលតំបន់សំរាប់ធ្វើការស្វែងរុករក និង/ឬធ្វើអាជីវកម្មធនធានរ៉ែនោះតាំងនៅ លើកលែងតែបែបបទនៃការដាក់ពាក្យសុំ និងការផ្តល់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ ដែលត្រូវកំណត់នៅក្នុងប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីប្រតិភូកម្មអំណាចនៃការងារឧស្សាហកម្ម រ៉ែ និងថាមពល ជូនដល់បណ្តាស្រុកនៃខេត្តមួយចំនួន ។

ខ- សំរាប់អាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត — ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណ នៅអគ្គនាយកដ្ឋានធនធានរ៉ែនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

បន្ទាប់ពីបានទទួលសំណុំលិខិតស្នើសុំគ្រប់គ្រាន់តាមបែបបទបច្ចេកទេស អគ្គនាយកដ្ឋានធនធានរ៉ែ និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវដាក់សំណុំលិខិតស្នើសុំនោះជូនរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ពិនិត្យ និងសំរេច ។

**ប្រការ ៤.-**

សំណុំលិខិតពាក្យសុំអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបានកំណត់ដូចខាងក្រោម :

៤.១ សំរាប់អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ និងអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ត្រូវរួមមាន :

(ក) ពាក្យសុំអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ ឬអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ (មានបិទតែម ១.០០០រៀល) ........ ចំនួន ១ច្បាប់

(ខ) ច្បាប់ចម្លងវិញ្ញាបនប័ត្រចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ឬនៅអគ្គនាយកដ្ឋានធនធានរ៉ែ ........ ចំនួន ១ច្បាប់

(គ) ប្លង់ទីតាំងស្នើសុំ (មានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន) ........ ចំនួន ១ច្បាប់

(ឃ) របាយការណ៍ស្តីពីសមត្ថភាពហិរញ្ញវត្ថុ (សំរាប់អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ) .. ចំនួន ១ច្បាប់

(ង) របាយការណ៍ពីកម្លាំងពលកម្ម និងឧបករណ៍សម្ភារៈ ........ ចំនួន ១ច្បាប់

៤.២ សំរាប់អាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត ត្រូវរួមមាន :

(ក) ពាក្យសុំអាជ្ញាប័ណ្ណធនធានរ៉ែ (មានបិទតែម ១.០០០រៀល) ........ ចំនួន ១ច្បាប់

(ខ) ច្បាប់ចម្លងវិញ្ញាបនប័ត្រចុះបញ្ជីនៅអគ្គនាយកដ្ឋានធនធានរ៉ែ ........ ចំនួន ១ច្បាប់

(គ) ប្លង់ទីតាំងស្នើសុំ (មានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន) ........ ចំនួន ១ច្បាប់

(ឃ) របាយការណ៍ស្តីពីសមត្ថភាពហិរញ្ញវត្ថុ ឬគុណភាពហិរញ្ញវត្ថុប្រចាំឆ្នាំចុងក្រោយ ៣ ឆ្នាំ របស់ក្រុមហ៊ុនដោយមានការបញ្ជាក់ពីស្ថាប័នហិរញ្ញវត្ថុ ឬសវនកម្មណាមួយ ដែលបានទទួលសិទ្ធិធ្វើអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា ........ ចំនួន ១ច្បាប់

(ង) កម្មវិធីការងារស្វែងរុករក/អាជីវកម្មធនធានរ៉ែ និងថវិកាសំរាប់ចំណាយនៅក្នុងរយៈពេលប្រតិបត្តិការធនធានរ៉ែ ........ ចំនួន ១ច្បាប់

(ច) បទពិសោធន៍កន្លងមករបស់ក្រុមហ៊ុនក្នុងវិស័យធនធានរ៉ែ ឬឧស្សាហកម្មពាក់ព័ន្ធ ចំនួន ១ច្បាប់

(ឆ) ការសិក្សាពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រង ផែនការស្តារឡើងវិញ និងថវិកាបំរុងសំរាប់ការស្តារឡើងវិញ ........ ចំនួន ១ច្បាប់

(ជ) ផែនការជ្រើសរើសពលករកម្ពុជា និងកម្មវិធីបណ្តុះបណ្តាល ........ ចំនួន ១ច្បាប់

**ប្រការ ៥.-**

សុពលភាពនៃអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបានកំណត់ ដូចខាងក្រោម :

១- អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ មានរយៈពេលមួយ (០១) ឆ្នាំ

២- អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម មានរយៈពេលមួយ (០១) ឆ្នាំ

៣- អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ មានរយៈពេលមួយ (០១) ឆ្នាំ

៤- អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ មានរយៈពេលមួយ (០១) ឆ្នាំ

៥- អាជ្ញាប័ណ្ណស្វែងរុករក មានរយៈពេលពីរ (០២) ឆ្នាំ ។

**ប្រការ ៦.-**

លក្ខខណ្ឌនៃការពន្យាបន្តអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបានកំណត់ដូចខាងក្រោម :

៦.១ សម្បទានិកដែលមានអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ អាចដាក់ពាក្យសុំអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែជាថ្មី រហូតដល់ជម្រករ៉ែអស់លក្ខណៈសេដ្ឋកិច្ច មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល តាមរយៈមន្ទីរ

ឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង ដើម្បីពិនិត្យ និងសំរេច យ៉ាងហោចណាស់សាមសិប (៣០) ថ្ងៃ មុនផុតសុពលភាពនៃអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែដែលកំពុងមាន ដោយអនុវត្តតាមកថាខ័ណ្ឌ ៤.១ នៃប្រការ ៤ ខាងលើ ។

៦.២ សម្បទានិកដែលមានអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ អាចដាក់ពាក្យសុំពន្យាបន្តអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីពិនិត្យ និងសំរេច យ៉ាងហោចណាស់សាមសិប (៣០) ថ្ងៃ មុនផុតសុពលភាពនៃអាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែដែលកំពុងមាន ដោយអនុវត្តតាមកថាខ័ណ្ឌ ៤.១ នៃប្រការ ៤ ខាងលើ ។

៦.៣ សម្បទានិកដែលមានអាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម ឬអាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ អាចដាក់ពាក្យសុំពន្យាបន្តរហូតដល់ជម្រករ៉ែអស់លក្ខណៈសេដ្ឋកិច្ច មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីពិនិត្យ និងសំរេច យ៉ាងហោចណាស់សាមសិប (៣០) ថ្ងៃ មុនផុតសុពលភាពនៃអាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម ឬអាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃដែលកំពុងមាន ដោយភ្ជាប់មកជាមួយនូវ :

(ក) លិខិតស្នើសុំការពន្យាបន្តអាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម ឬ អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ............................................ ចំនួន ១ច្បាប់

(ខ) របាយការណ៍ស្តីពីលទ្ធផលនៃការស្វែងរុករក និង/ឬការធ្វើអាជីវកម្មធនធានរ៉ែ ដែលបានអនុវត្តក្នុងរយៈពេលនៃអាជ្ញាប័ណ្ណមុន .................................... ចំនួន ១ច្បាប់

(គ) របាយការណ៍ស្តីពីការការពារបរិស្ថាននៅក្រៅនិងក្នុងការដ្ឋានរ៉ែ និងការអនុវត្តនីកម្មវិធីស្តារឡើងវិញដោយមានការបញ្ជាក់ពីមន្ទីរបរិស្ថានខេត្ត/ក្រុង ........... ចំនួន ១ច្បាប់

(ឃ) តុល្យភាពគណនីសំរាប់មូលនិធិស្តារឡើងវិញ និងមូលនិធិបណ្តុះបណ្តាល ........ ចំនួន ១ច្បាប់

(ង) របាយការណ៍ស្តីពីការបង់ជូនរដ្ឋនូវសួយសារ ឈ្នួលដីប្រចាំឆ្នាំ និងពន្ធអាករពាក់ព័ន្ធ ដោយភ្ជាប់មកជាមួយនូវច្បាប់ចម្លងសក្ខីប័ត្រដើម ................................ ចំនួន ១ច្បាប់

(ច) ផែនការស្វែងរុករក និង/ឬអាជីវកម្មធនធានរ៉ែ ផែនការស្តារការដ្ឋានរ៉ែឡើងវិញ និងកម្មវិធីបណ្តុះបណ្តាល សំរាប់រយៈពេលពន្យាបន្ត ................ ចំនួន ១ច្បាប់

៦.៤ សម្បទានិកដែលមានអាជ្ញាប័ណ្ណស្វែងរុករក អាចសុំពន្យាបន្តរយៈពេលស្វែងរុករកបានពីរ (០២) ដង ដោយម្តងៗមានរយៈពេលពីរ (០២) ឆ្នាំ ។ សម្បទានិកត្រូវដាក់ពាក្យសុំពន្យាបន្តអាជ្ញាប័ណ្ណស្វែងរុករក មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីពិនិត្យ និងសំរេច យ៉ាងហោចណាស់សាមសិប (៣០) ថ្ងៃ មុនផុតសុពលភាពនៃអាជ្ញាប័ណ្ណស្វែងរុករកដែលកំពុងមាន ដោយភ្ជាប់មកជាមួយនូវ :

(ក) លិខិតស្នើសុំការពន្យាបន្តអាជ្ញាប័ណ្ណស្វែងរុករក ........................................ចំនួន ១ច្បាប់

(ខ) របាយការណ៍ស្តីពីលទ្ធផលនៃការស្វែងរុករកធនធានរ៉ែ ដែលបានអនុវត្តនៅក្នុងរយៈពេលនៃអាជ្ញាប័ណ្ណមុន .................................................... ចំនួន ១ច្បាប់

(គ) របាយការណ៍ស្តីពីការការពារបរិស្ថាននៅក្រៅនិងក្នុងការដ្ឋានរ៉ែ និងការអនុវត្តនីកម្មវិធីស្តារឡើងវិញដោយមានការបញ្ជាក់ពីមន្ទីរបរិស្ថានខេត្ត/ក្រុង ........... ចំនួន ១ច្បាប់

(ឃ) របាយការណ៍ស្តីពីការបង់ជូនរដ្ឋនូវឈ្នួលដីប្រចាំឆ្នាំ និងពន្ធអាករពាក់ព័ន្ធផ្សេងទៀត ដោយភ្ជាប់មកជាមួយនូវច្បាប់ចម្លងសក្ខីប័ត្រដើម ........................... ចំនួន ១ច្បាប់

(ង) ផែនការស្វែងរុករក និងកម្មវិធីបណ្តុះបណ្តាលសំរាប់រយៈពេលបន្ត ............... ចំនួន ១ច្បាប់

នៅចុងបញ្ចប់នៃឆ្នាំទីប្រាំមួយ (០៦) ឬ នៅឆ្នាំចុងក្រោយនៃអាជ្ញាប័ណ្ណស្វែងរុករករ៉ែ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាចពន្យាបន្តនៃអាជ្ញាប័ណ្ណនេះ សំរាប់រយៈពេលបន្ថែមតំណាក់មួយ ក្នុងករណី

ដែលសម្បទានិកត្រូវការពេលវេលា ដើម្បីសិក្សាពីលទ្ធភាពសេដ្ឋកិច្ចនៃជម្រករ៉ែ ឬដើម្បីដាក់ពាក្យសុំអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ នៅក្នុងតំបន់ដែលស្ថិតនៅក្នុងរង្វង់ព្រំដែននៃអាជ្ញាប័ណ្ណស្វែងរុករកនោះ ។

**ប្រការ ៧.-**

នៅពេលផុតសុពលភាពនៃអាជ្ញាប័ណ្ណធនធានរ៉ែ ប្រសិនបើសម្បទានិកណាមួយមិនបានដាក់ពាក្យសុំអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែជាថ្មី ឬពាក្យសុំពន្យារបន្តអាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត ដូចបានកំណត់ក្នុងប្រការ ៦ ខាងលើ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នឹងដកតំបន់សម្បទាននោះមកវិញទាំងស្រុង ។ ក្នុងករណីនេះ សម្បទានិកនោះត្រូវទទួលខុសត្រូវក្នុងការជំរះបំណុលពាក់ព័ន្ធទាំងអស់ដែលរួមមានជាអាទិ៍ សួយសារ ឈ្នួលដីប្រចាំឆ្នាំ ពន្ធលើប្រាក់ចំណេញ និងពន្ធអាករពាក់ព័ន្ធផ្សេងទៀត និងមូលនិធិសំរាប់ការស្តារឡើងវិញដែលនៅសល់ មុនពេលផុតសុពលភាពនៃអាជ្ញាប័ណ្ណធនធានរ៉ែ ព្រមទាំងត្រូវទទួលខុសត្រូវក្នុងការស្តារការដ្ឋានរ៉ែទាំងឡាយ ដែលស្ថិតនៅក្រោមអាជ្ញាប័ណ្ណធនធានរ៉ែនោះ ។

**ប្រការ ៨.-**

ក្នុងករណីពុំទាន់មានអនុក្រឹត្យស្តីពីការផ្តល់អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ សម្បទានិកដែលមានអាជ្ញាប័ណ្ណស្វែងរុករក អាចដាក់ពាក្យសុំអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ឬសុំពន្យារបន្ត ក្រោមលក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងស្វែងរុករកនិង/ឬធ្វើអាជីវកម្មធនធានរ៉ែ ដែលបានចុះហត្ថលេខារវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង សម្បទានិកនោះ ។

**ប្រការ ៩.-**

លើកលែងតែអាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ សម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែផ្សេងទៀត ហើយដែលមានបំណងផ្ទេរសិទ្ធិទាំងស្រុងនៃអាជ្ញាប័ណ្ណធនធានរ៉ែនោះ ទៅឱ្យភាគីមួយទៀត ត្រូវដាក់ពាក្យសុំផ្ទេរសិទ្ធិ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីពិនិត្យ និងសំរេច ដោយភ្ជាប់មកជាមួយនូវ :

(ក) លិខិតស្នើសុំផ្ទេរសិទ្ធិទាំងស្រុងនៃអាជ្ញាប័ណ្ណធនធានរ៉ែ ពីភាគីផ្ទេរសិទ្ធិ ដោយមានការបញ្ជាក់មូលហេតុច្បាស់លាស់ ........................................ ចំនួន ១ច្បាប់

(ខ) លិខិតស្នើសុំទទួលសិទ្ធិ និងការទទួលខុសត្រូវទាំងស្រុង ពីភាគីទទួលសិទ្ធិ ដោយមានការបញ្ជាក់មូលហេតុច្បាស់លាស់ ........................................ ចំនួន ១ច្បាប់

(គ) របាយការណ៍ស្តីពីការជំរះបំណុលសួយសារ ឈ្នួលដីប្រចាំឆ្នាំ និងពន្ធអាករពាក់ព័ន្ធផ្សេងទៀត ដោយភ្ជាប់មកជាមួយនូវច្បាប់ចម្លងសក្ខីប័ត្រដើម .................. ចំនួន ១ច្បាប់

(ឃ) ច្បាប់ចម្លងវិញ្ញាបនប័ត្រចុះបញ្ជីរបស់ភាគីទទួលសិទ្ធិ នៅអគ្គនាយកដ្ឋានធនធានរ៉ែ ........................................................... ចំនួន ១ច្បាប់

(ង) របាយការណ៍ស្តីពីសមត្ថភាពហិរញ្ញវត្ថុ ឬតុល្យភាពហិរញ្ញវត្ថុប្រចាំឆ្នាំចុងក្រោយ ៣ឆ្នាំ របស់ភាគីទទួលសិទ្ធិ ដោយមានការបញ្ជាក់ពីស្ថាប័នហិរញ្ញវត្ថុ ឬ សវនកម្មណាមួយដែលបានទទួលសិទ្ធិធ្វើអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា ........................ ចំនួន ១ច្បាប់

(ច) បទពិសោធន៍កន្លងមករបស់ភាគីទទួលសិទ្ធិ ក្នុងវិស័យធនធានរ៉ែ ឬឧស្សាហកម្មដែលពាក់ព័ន្ធ ........................................................................... ចំនួន ១ ច្បាប់

(ឆ) កម្មវិធីការងារស្វែងរុករក/អាជីវកម្មធនធានរ៉ែ និងថវិកាសំរាប់ចំណាយរបស់ភាគីទទួលសិទ្ធិ នៅក្នុងរយៈពេលប្រតិបត្តិការធនធានរ៉ែ ........................ ចំនួន ១ច្បាប់

(ជ) ការសិក្សាពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រង ផែនការស្តារឡើងវិញ និងថវិកាបំរុងសំរាប់ការស្តារឡើងវិញ របស់ភាគីទទួលសិទ្ធិ ........................ ចំនួន ១ ច្បាប់

(ឈ) ផែនការជ្រើសរើសពលករកម្ពុជា និងកម្មវិធីបណ្តុះបណ្តាលរបស់ភាគីទទួលសិទ្ធិ ចំនួន ១ ច្បាប់

**ប្រការ ១០.-**

ក្នុងករណីអាជ្ញាប័ណ្ណធនធានរ៉ែត្រូវបានព្យួរទុក ឬដកហូត សម្បទានិកត្រូវទទួលខុសត្រូវក្នុងការជំរះបំណុលពាក់ព័ន្ធទាំងអស់ដែលរួមមានជាអាទិ៍ សួយសារ ឈ្នួលដីប្រចាំឆ្នាំ ពន្ធលើប្រាក់ចំណេញ និងពន្ធអាករពាក់ព័ន្ធផ្សេងទៀត និងមូលនិធិសំរាប់ការស្តារឡើងវិញដែលនៅសល់មុនពេលព្យួរទុក ឬដកហូតអាជ្ញាប័ណ្ណធនធានរ៉ែ ព្រមទាំងត្រូវទទួលខុសត្រូវក្នុងការស្តារការដ្ឋានរ៉ែទាំងឡាយដែលស្ថិតនៅក្រោមអាជ្ញាប័ណ្ណធនធានរ៉ែនោះ ។

**ប្រការ ១១.-**

អគ្គនាយកដ្ឋានធនធានរ៉ែ និងមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

**ប្រការ ១២.-**

ប្រកាសនេះ មានប្រសិទ្ធភាព និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

**ស៊ុយ-សែម**

**ចម្លងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ខេត្ត-ក្រុង (ដើម្បីជូនជ្រាប)
- ដូចប្រការ ១១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ